**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្ដីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្ដីពី
## ករណីព្យាបាលជាសះស្បើយ ០១នាក់ និងមានករណីវិជ្ជមានកូវីដ-១៩ ថ្មី ០៩នាក់ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **ចំនួនអ្នកព្យាបាលជាសះស្បើយ** សរុបទូទាំងប្រទេស មានចំនួន **១២៩នាក់** (ស្មើនឹង ៩២,៨១% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងបុរស ៩០នាក់
- **អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត** សរុបមានចំនួន ១០នាក់ ដែលមាន ៖
  - បុរសជនជាតិខ្មែរ ០៨នាក់ ស្ត្រីជនជាតិខ្មែរ ០១នាក់ និងបុរសជនជាតិឥណ្ឌូណេស៊ី ០១នាក់ ដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ី
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** នៅទូទាំងប្រទេស សរុបចំនួន **១៣៩នាក់** (ស្ត្រី ៤០នាក់ និងបុរស ៩៩នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០១នាក់

បុរសខ្មែរ-អាមេរិកកាំង អាយុ ៦៦ឆ្នាំ ជាអ្នករស់នៅសហរដ្ឋអាមេរិក បានធ្វើដំណើរមកកម្ពុជា និងមានអាស័យដ្ឋានស្នាក់នៅរាជធានីភ្នំពេញ បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** ចំនួន ០៩នាក់ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

ស្ត្រីជនជាតិខ្មែរអាយុ ២៩ឆ្នាំ (០១នាក់) បុរសជនជាតិខ្មែរ អាយុ ២៣ឆ្នាំ (០១នាក់) អាយុ២៤ឆ្នាំ (០១នាក់) អាយុ២៥ឆ្នាំ (០២នាក់) អាយុ២៦ឆ្នាំ (០៣នាក់) និងបុរសជនជាតិឥណ្ឌូណេស៊ីអាយុ ២២ឆ្នាំ (០១នាក់) ដែលបុគ្គលទាំង ០៩នាក់នេះ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី តាមជើងហោះហើរត្រង់ បានមកដល់កម្ពុជានៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ធ្វើវិភាគវត្ថុសំណាកពួកគាត់នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ទទួលបានលទ្ធផលតេស្ត វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ទាំង ០៩នាក់។



ទីស្ដីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

សម្គាល់៖ ជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ៤០នាក់ (ស្ត្រី ១០នាក់ និងបុរស ៣០នាក់) ដោយនៅក្នុងចំនួន ៤០នាក់នេះ មានអ្នកដំណើរជាជនជាតិខ្មែរចំនួន ២៤នាក់ (ស្រី ០៨នាក់) ជនជាតិវៀតណាមចំនួន ០១នាក់ (ស្រី) និងជនជាតិឥណ្ឌូណេស៊ីចំនួន ១៥នាក់ (ស្រី ០១នាក់) ដែលបានធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី។

អ្នកដំណើរនៅសល់ចំនួន ៣១នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបន្តធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដោយចែកចេញជា៖

- អ្នកដំណើរជនជាតិខ្មែរចំនួន ១៥នាក់ (ស្រី ០៧នាក់) ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យនៅមណ្ឌលរងចាំមូលដ្ឋានទ័ពអាកាស ដើម្បីរងចាំការដឹកជញ្ជូនទៅបន្តធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅតាមបណ្តាខេត្តដែលពួកគាត់រស់នៅរៀងៗខ្លួន
- រីឯអ្នករស់នៅទីក្រុងភ្នំពេញ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កនៅមណ្ឌលសុខភាពចាក់អង្រែក្រោម
- ចំណែកឯអ្នកដំណើរដែលជាជនជាតិឥណ្ឌូណេស៊ី និងវៀតណាម សរុបទាំងអស់ ១៦នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ នោះ ត្រូវបានជ្រើសរើសបង់ថ្លៃស្នាក់នៅធ្វើចត្តាឡីស័កនៅសណ្ឋាគារមួយក្នុងទីក្រុងភ្នំពេញ ដើម្បីតាមដានសុខភាពបន្តទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៥៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ៧កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០**

**ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ១៣៩ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០**

**ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ១៣៩ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល